ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៣៣ ត្រីមាសទី០២ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន
ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-៦-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៦២១/៤៦៨ ស្តីពី និយ័តកម្មក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ និងកម្រិតសញ្ញាបត្រ នៅក្រសួងមួយចំនួន ដល់មន្ត្រីរាជការ ៣៧ រូប ៣៩៨៣

១២-៦-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៦២១/៤៦៩ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ហឿន សំនៀង** ជានាយកវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន ៣៩៨៦

១២-៦-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៦២១/៤៧០ ស្តីពី ការតែងតាំងមុខតំណែងលោកជំទាវ **ថាក់ ឡានី** ជារដ្ឋលេខាធិការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ៣៩៨៧

១២-៦-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៦២១/៤៧១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ថៃ ម៉ុនថន** ពីប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ពន្ធនឹងវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឋានៈស្មើ អគ្គរាជទូត និងតែងតាំងមុខតំណែងឯកឧត្តម **ឡុង កែមវិចិត្រ** ជាប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឋានៈស្មើ អគ្គរាជទូត ៣៩៨៨

១២-៦-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៦២១/៤៧២ ស្តីពី ការបញ្ចប់មុខតំណែងលោកជំទាវ **ខិន ផលរ័ត្ន** ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ៣៩៨៩

១២-៦-២០២១ -ព្រះរាជក្រឹត្យ នស/រកត/០៦២១/៤៧៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **គីម ហ្យុនអា (KIM HYUN AH)** ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ដោយប្តូរឈ្មោះជា **គីម សុជាតា (KIM SOCHEATA)** ៣៩៩០


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៤-៦-២០២១ -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៣៩៩១

៧-៦-២០២១ -អនុក្រឹត្យលេខ ២៧១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៩៩៣

៨-៦-២០២១ -អនុក្រឹត្យលេខ ២៧៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៣៩៩៤

៨-៦-២០២១ -អនុក្រឹត្យលេខ ២៧៩ អនក្រ.តត ស្តីពី ការនិយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការ ៣៩៩៦

៩-៦-២០២១ -អនុក្រឹត្យលេខ ២៨២ អនក្រ.តត ស្តីពី ការតែងតាំង ប្រគល់ភារកិច្ច និងសម្រួលភារកិច្ច មន្ត្រីរាជការ ៣៩៩៨

១៤-៦-២០២១ -អនុក្រឹត្យលេខ ២៨៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ៤០០០

## ២~សេចក្តីសម្រេច

១៩-៦-២០២១ -សេចក្តីសម្រេចលេខ ៧០ សសរ ស្តីពី ការតែងតាំងសមាសភាពនៃអនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ៤០០២

## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២១-១០-២០២០ -ប្រកាសលេខ ៥៣២ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ារ៉ល ហ្វាមិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤០១៥

២៧-១០-២០២០ -ប្រកាសលេខ ៥៣៧ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កាល់លីស្តូ អឺភើរឹល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤០១៨

២៧-១០-២០២០ -ប្រកាសលេខ ៥៣៨ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អមនី អេប៉រ សីលូសិន បង្កើតរោងចក្រ ផលិតក្តារកុងប្លាកេ និងក្តារបន្ទះ ៤០២១

២៧-១០-២០២០ -ប្រកាសលេខ ៥៣៩ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មូន អឺភើរឹល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤០២៤

២៧-១០-២០២០ -ប្រកាសលេខ ៥៤០ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជាំងស៊ុ ៣អិល មេឌីខល ប្រដាក់ គ្រុប (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្ភារៈពេទ្យ ៤០២៧

២៧-១០-២០២០ -ប្រកាសលេខ ៥៤១ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជី.ស៊ី.អេច អ៊ិនធើណេសិនណល ត្រេដ ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ៤០៣០

២៨-១០-២០២០ -ប្រកាសលេខ ៥៤២ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីយ៉ីង (ខេមបូឌា) អ៊ិនដាសស្ទ្រៀល ឯ.ក បង្កើតរោងចក្រ ផលិតឆ័ត្រ អាវភ្លៀង វាំងនន និងកម្រាលតុបាយ ៤០៣៣

២៨-១០-២០២០ -ប្រកាសលេខ ៥៤៣ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូ វ៉ាយដ៍ (ខេមបូឌា) ហ្គាមេន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤០៣៦

២៨-១០-២០២០ -ប្រកាសលេខ ៥៤៤ ឧវបន.កឧ.ប្រក ១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេនេរ៉ល ស្ទៀល អ៊ិនធើណេសិនណល (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កែច្នៃដែក ៤០៣៩

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ២៣-៤-២០២០ | -ប្រកាសលេខ ០១៤៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០១៤៧ រថ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០ | ៤០៤២ |
| ២៣-៤-២០២០ | -ប្រកាសលេខ ០១៤៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៤៨ រថ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០២០ | ៤០៤៦ |
| ២៣-៤-២០២០ | -ប្រកាសលេខ ០១៤៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៤៩ រថ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០២០ | ៤០៥០ |
| ២៨-៤-២០២០ | -ប្រកាសលេខ ០១៥១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៥១ រថ.អប្រក.លអ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០២០ | ៤០៥៤ |
| ២៨-៤-២០២០ | -ប្រកាសលេខ ០១៥២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០១៥២ រថ.អប្រក.លអ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២០ | ៤០៥៨ |
| ២៨-៤-២០២០ | -ប្រកាសលេខ ០១៥៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៥៣ រថ.អប្រក.លអ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០២០ | ៤០៦២ |
| ៣០-៤-២០២០ | -ប្រកាសលេខ ០១៥៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៥៤ រថ.អប្រក.លអ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០ | ៤០៦៦ |
| ២៤-៦-២០២០ | -ប្រកាសលេខ ០១៨០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៨០ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០២០ | ៤០៧០ |


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ


| | | |
|---|---|---|
| ១៦-៦-២០២០ | -ប្រកាសលេខ ២៧៥០ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម | ៤០៧៤ |
| ២-៧-២០២០ | -ប្រកាសលេខ ២៩០២ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម | ៤០៧៥ |
| ២-៧-២០២០ | -ប្រកាសលេខ ២៩០៣ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម | ៤០៧៦ |
| ៩-៧-២០២០ | -ប្រកាសលេខ ៣០០២ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម | ៤០៧៧ |
| ១៧-៧-២០២០ | -ប្រកាសលេខ ៣០៨៨ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម | ៤០៧៨ |
| ១៧-៧-២០២០ | -ប្រកាសលេខ ៣០៨៩ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម | ៤០៧៩ |
| ២០-៧-២០២០ | -ប្រកាសលេខ ៣១២១ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម | ៤០៨០ |


## ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌


| | | |
|---|---|---|
| ១៨-១-២០២១ | -ប្រកាសលេខ ០៣៥ កយ.ប្រក/២១ ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ | ៤០៨១ |

| | | |
|---|---|---|
| ១៨-១-២០២១ | -ប្រកាសលេខ ០៣៦ កយ.ប្រក/២១ ស្ដីពី ការលុបឈ្មោះមន្ត្រីរាជការ | ៤០៨៣ |
| ២១-១-២០២១ | -ប្រកាសលេខ ០៣៧ កយ.ប្រក/២១ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ | ៤០៨៥ |
| ២៦-១-២០២១ | -ប្រកាសលេខ ០៣៩ កយ.ប្រក/២១ ស្ដីពី ការលុបឈ្មោះមន្ត្រីរាជការ | ៤០៩១ |
| ១-២-២០២១ | -ប្រកាសលេខ ០៤១ កយ.ប្រក/២១ ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ៤០៩២ |
| ១-២-២០២១ | -ប្រកាសលេខ ០៤២ កយ.ប្រក/២១ ស្ដីពី ការផ្លាស់មន្ត្រីរាជការ | ៤០៩៤ |
| ៩-២-២០២១ | -ប្រកាសលេខ ០៤៧ កយ.ប្រក/២១ ស្ដីពី ការផ្ទេរភារកិច្ច តែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ | ៤០៩៥ |
| ៩-២-២០២១ | -ប្រកាសលេខ ០៤៨ កយ.ប្រក/២១ ស្ដីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៤០៩៧ |
| ៩-២-២០២១ | -ប្រកាសលេខ ០៤៩ កយ.ប្រក/២១ ស្ដីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ | ៤០៩៩ |

**៥~ទីស្តីការក្រសួងធម្មការ និង សាសនា**

| | | |
|---|---|---|
| ៣-៩-២០២០ | -សេចក្ដីសម្រេចលេខ ៤៨/២០ ក.ធ.ស.សសរ ស្ដីពី ការអនុញ្ញាតឱ្យកសាងព្រះវិហារ | ៤១០១ |
| ៣-៩-២០២០ | -ប្រកាសលេខ ៨៩/២០ ក.ធ.ស.ប្រក ស្ដីពី ការប្រែកាយអាស្រមទៅជាវត្តនៃគណៈមហានិកាយ | ៤១០៣ |
| ៥-២-២០២១ | -ប្រកាសលេខ ២១/២១ ក.ធ.ស.ប្រក ស្ដីពី ការបង្កើតវត្ត នៃគណៈធម្មយុត្តិកនិកាយ | ៤១០៥ |

# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/៤៦៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** និយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងចំនួន ០៤ ដល់មន្ត្រីរាជការ ១៥ រូប ៖

**ក -ក្រសួងព័ត៌មាន**

១-លោក **អេង តេងឈុន** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៥

**ខ-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១-លោកស្រី **សៅ សុគន្ធតេវ្យា** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ មកជា ថ្នាក់លេខ ១

២-លោក **សោម សុវណ្ណរិទ្ធ** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ មកជា ថ្នាក់លេខ ២

៣-លោក **ឈិន ច័ន្ទវិបុល** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦

៤-លោក **អ៊ុក ដាវ៉ាន់ឌី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ១

៥-លោក **ហុង សុគន្ធ** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ១

៦-លោកស្រី **ហ៊ូ សុគន្ធវារី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ១

៧-លោកស្រី **សុខ ម៉ិនឈាង** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៤

៨-លោកស្រី **ឡុង សុផាន** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៤

៩-លោក **ជួប គឹមសាន** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥

**គ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

១-លោក **តាច់ ម៉ាខ្មៅ** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ១

២-លោក **សួន លក្សស្មី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ១

៣-លោក **ស្វ សុខុន** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ មកជា ថ្នាក់លេខ ៣

៤-លោក **ហុង ពៅ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤

**ឃ-ក្រសួងយុត្តិធម៌**

១-ឯកឧត្តម **ឈន ព្រាលីង** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ មកជា ថ្នាក់លេខ ២

**មាត្រា ២ :** និយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ និងកម្រិតសញ្ញាបត្រ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងចំនួន ០៤ ដល់មន្ត្រីរាជការ ២២ រូប ៖

**ក-ក្រសួងព័ត៌មាន**

១-លោក **ឱុច ណាង** ពីនាយក្រមការ ថ្នាក់លេខ ១ មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៥

២-លោកស្រី **ម៉ុ ចាន់រស្មី** ពីក្រមការ ថ្នាក់លេខ ១ មកជាអនុមន្ត្រី ថ្នាក់លេខ ១

៣-លោកស្រី **អ៊ុក ច័ាន់ធឿន** ពីក្រមការដើមខ្សែ ថ្នាក់លេខ ១ មកជាអនុមន្ត្រី ថ្នាក់លេខ ៣

៤-លោកស្រី **ម៉េន គីមហ៊ាន់** ពីក្រមការ ថ្នាក់លេខ ១ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

៥-លោក **គារ អ៊ុយឡាយ** ពីក្រមការ ថ្នាក់លេខ ១ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

៦-លោកស្រី **អ៊ុង គីមហ៊ន** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៧ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

៧-លោកស្រី **ពេជ បុទុម** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

**ខ-ក្រសួងមហាផ្ទៃ**

១-លោក **រស់ តុលា** ពីក្រមការដើមខ្សែ ថ្នាក់លេខ ៣ មកជាអនុមន្ត្រី ថ្នាក់លេខ ១

២-លោក **ប៉េង សុខឃៀង** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

៣-លោក **យស សុផាត** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

៤-លោកស្រី **ប្រាក់ ធទី** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

**គ-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១-លោក **ធេស ម៉េត** ពីនាយក្រមការ ថ្នាក់លេខ ៤ មកជាវរមន្ត្រី ថ្នាក់លេខ ២

២-លោក **សន ខេមរា** ពីគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៤
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

៣-លោក **ឡុត គុយហេង** ពីគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៤
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

៤-លោក **សុខ គុណា** ពីគ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៥
មកជាគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤

៥-លោក **ស៊ុំ សុផា** ពីគ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤

៦-លោក **សឹម សុវណ្ណនា** ពីគ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៣
មកជាគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤

៧-លោកស្រី **សឹម សុសិតា** ពីគ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៣
មកជាគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤

**ឃ-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

១-លោកស្រី **ម៉ែន ពិដោរ** ពីក្រមការដើមខ្សែ ថ្នាក់លេខ ២ មកជាអនុមន្ត្រី ថ្នាក់លេខ ១

២-លោក **ជិន សុវណ្ណារិទ្ធ** ពីក្រមការដើមខ្សែ ថ្នាក់លេខ ៤ មកជាអនុមន្ត្រី ថ្នាក់លេខ ៣

៣-លោក **កែវ សុវត្ថិ** ពីក្រមការ ថ្នាក់លេខ ២ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

៤-លោក **ឃិន ឫទ្ធី** ពីក្រមការ ថ្នាក់លេខ ៣ មកជាអនុមន្ត្រី ថ្នាក់លេខ ៤

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នសរកត.០៦២១.៥៧២

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២១*

បានបម្រុងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

៧/៣

កិត្តិនីតិកោសល្យបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/៤៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងមុខតំណែងឯកឧត្តម **ហឿន សំនៀង** ជានាយកវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* **១២** *ខែ មិថុនា ឆ្នាំ ២០២១*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/ ៤៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងលោកជំទាវ **ថាក់ ឡានី** ជារដ្ឋលេខាធិការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចរស.២២០៦.៤៧៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២១

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/៤៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចប់មុខតំណែងឯកឧត្តម **ថៃ ប៊ុនថន** ពីប្រធានស្ថានបេសកកម្មស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឋានៈជា **អគ្គរាជទូត**។

**មាត្រា២** : តែងតាំងមុខតំណែងឯកឧត្តម **ឡុង កែមវិចិត្រ** ជាប្រធានស្ថានបេសកកម្មស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឋានៈជា **អគ្គរាជទូត**។

**មាត្រា៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣១៧.២១០៦.៤៧៥

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/៤៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចប់មុខតំណែងលោកជំទាវ **ខិន ផលរ័ត្ន** ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរក.០៦២១.៤៧៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២១*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/៤៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **គីម ហ្យុនអា** (KIM HYUN AH) ជនជាតិ កូរ៉េ សញ្ជាតិ កូរ៉េ កើតនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៦២ នៅខេត្តចុលឡាណាំដូ សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម សុជាតា** (KIM SOCHEATA)។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៩៩.២០២១.៤៧៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានបង្គំថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ក្នុងជំពូក ២១ (គម្រោងវិនិយោគផ្ទាល់)ចំនួន ៤២០ ០០០ លានរៀល (បួនរយម្ភៃពាន់លានរៀលគត់) ពីខ្ទង់ឥណទានថវិកាមិនទាន់បែងចែកអចលកម្មរូបី ជូនក្រសួងសាធារណការនិងដឹកជញ្ជូន ។

មាត្រា២._

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា៣._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០២១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៣៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **សំ ពិសិដ្ឋ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកចំការលើ ខេត្តកំពង់ចាម។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១២ រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០២១ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៧៨ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០២រូប ឱ្យទៅកាន់មុខតំណែងជាអភិបាលស្រុក នៃខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោមៈ

១-លោក **សូ សាហុខ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ពីអភិបាលស្រុកភ្នំក្រវាញ ឱ្យទៅកាន់មុខតំណែងជាអភិបាលស្រុកវាលវែង

២-លោក **ហោខ សុភាណា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ពីអភិបាលស្រុកវាលវែង ឱ្យទៅកាន់មុខតំណែងជាអភិបាលស្រុកភ្នំក្រវាញ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ២៧៩ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការនិយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : និយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ដល់មន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោមៈ

១-លោក **សុខ ចន្ទារិទ្ធ** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ១ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ។

២-លោក **ទុំ នី** ពីឋាននន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១ មកជាឋាននន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៨២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំង ប្រគល់ភារកិច្ច និងសម្រួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំង ប្រគល់ភារកិច្ច និងសម្រួលភារកិច្ច មន្ត្រីរាជការចំនួន ០៤ រូប របស់វិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដូចមានរាយនាមខាងក្រោម ៖

១-លោក **ប្រាជ្ញហាក់ សេរីរិទ្ធ** ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជានាយករងវិទ្យាស្ថាន

២-លោក **ឃិន សិរីវុធ** សម្រួលភារកិច្ចពីប្រធានវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស សាធារណការ និងដឹកជញ្ជូន ទៅជាប្រធាននាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍ

៣-លោកស្រី **ប្រសើរ ម៉ូលីកា** សម្រួលភារកិច្ចពីប្រធាននាយកដ្ឋាននីតិកម្ម មកជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ

៤-លោកស្រី **ញឹក ច័ន្ទវណ្ណារ៉ា** ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤ រោច ខែ ជេស្ឋ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៥៥ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា ១**.-ត្រូវបានតែងតាំងមន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ចំនួន ០៩រូប ដូចខាងក្រោម÷

| | |
|---|---|
| ១-លោក **ទៅ ដាឡែន** | ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានឋានៈស្មើ អគ្គនាយករង |
| ២-លោក **នង ពិសិដ្ឋ** | ជាអគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច |
| ៣-លោក **ណី សារកល** | ជាអគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច |
| ៤-លោក **អ៊ុន មាត្រា** | ជាអគ្គនាយករងនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ |

៥- លោកស្រី **ហេង ច័ន្ទសុតា** ជាអគ្គនាយករងនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ

៦- លោក **សោម ផៃ** ជាអគ្គនាយករងនៃនិយ័តករធានារ៉ាប់រងកម្ពុជា

៧- លោកស្រី **ហោ សុទ្ធឡេនា** ជាអគ្គនាយករងនៃនិយ័តករធានារ៉ាប់រងកម្ពុជា

៨- លោក **ឈុំ សេរីទុង** ជាអនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានឋានៈស្មើ អគ្គនាយករង

៩- លោក **គាត ហេង** ជាអនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានឋានៈស្មើ អគ្គនាយករង។

**មាត្រា ២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៧០ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពនៃអនុគណៈកម្មការនានា ចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្ដីសម្រេចលេខ ៦៩ សសរ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីសមាសភាព និងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមសំណើរបស់ប្រធានគណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ ..**

តែងតាំងសមាសភាពនៃអនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដូចមានរាយនាមខាងក្រោម៖

### I-អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រ

| | | |
|---|---|---|
| ១-ឯកឧត្តមវេជ្ជបណ្ឌិត **ឡូ វាសនាគិរី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២-ឯកឧត្តម **ទូន ថាវរៈ** | រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| ៣-ឯកឧត្តម **ជិន ម៉ាលីន** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-ឯកឧត្តម **ហេង សួរ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៥-ឯកឧត្តម **សំហេង បូរស** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៦-ឯកឧត្តម **ហេង សុខគង់** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៧-ឯកឧត្តម **ចាន់ សុធា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៨-ឯកឧត្តម **ហ្វូត ពុំ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៩-ឯកឧត្តម **សាន វឌ្ឍនា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ១០-ឯកឧត្តម **សុខ សទ្វារ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ១១-ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ឹង វណ្ណារុំ** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធានអចិន្ត្រៃយ៍ |
| ១២-ឯកឧត្តម **គាន់ហ៊ាង ដាវ័ណ្ណា** | អគ្គនាយកអភិវឌ្ឍន៍វិស័យយុត្តិធម៌ក្រសួងយុត្តិធម៌ | សមាជិក |
| ១៣-ឯកឧត្តមវេជ្ជបណ្ឌិត **ហុក គឹមចេង** | អគ្គនាយកបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល | សមាជិក |
| ១៤-ឯកឧត្តមសាស្ត្រាចារ្យ **សាផុន វឌ្ឍនៈ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ១៥-ឯកឧត្តម **អាំង សុវណ្ណរ័ត្ន** | អគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងទេសចរណ៍ | សមាជិក |
| ១៦-លោកសាស្ត្រាចារ្យ **ចាប សៀកឆាយ** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងសុខាភិបាល | សមាជិក |
| ១៧-លោក **ញ៉ាំ ស៊ីនិត** | អគ្គនាយករងគោលនយោបាយ និងផែនការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

១៨-ឯកឧត្តមវេជ្ជបណ្ឌិត **លី សូវ៉ាន់** ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល សមាជិក

១៩-ឯកឧត្តមសាស្ត្រាចារ្យ **ឈា ឆវណ្ណា** នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ សមាជិក

២០-ឯកឧត្តម **ឃ្លោក ដារ៉ា** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងដៃគូអភិវឌ្ឍន៍ ក្រសួងយុត្តិធម៌ សមាជិក

២១-លោកវេជ្ជបណ្ឌិត **ឈិត សុផល** ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្តនិងបំពានគ្រឿងញៀន ក្រសួងសុខាភិបាល សមាជិក

២២-លោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** ប្រធាននាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល សមាជិក

២៣-លោកវេជ្ជបណ្ឌិត **លី ចិដ្ចារ៉ាឌុច** ប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល ក្រសួងសុខាភិបាល សមាជិក

២៤-លោក **សុ សោភ័ណវិចិត្រ** មន្ត្រីស្រាវជ្រាវជាន់ខ្ពស់នៃអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២៥-លោកស្រីសាស្ត្រាចារ្យជំនួយ **ឈា ឆដាតា** ប្រធានមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព ក្រសួងសុខាភិបាល សមាជិក

២៦-លោកសាស្ត្រាចារ្យមហាបរិញ្ញា **អ៊ុច តឹកឆេង** អនុប្រធានការិយាល័យបច្ចេកទេស មន្ទីរពេទ្យកុមារជាតិ សមាជិក

២៧-កញ្ញា **ឈួន មរកត** ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្មនិងយុត្តិធម៌ ក្រសួងយុត្តិធម៌ សមាជិក។

**II-អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក**

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ីង ម៉ានិត** អគ្គនាយកស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ ប្រធាន

២-ឯកឧត្តមនាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍

៣-ឯកឧត្តម **សរ សុវណ្ណា** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៤-ឯកឧត្តម **ឌិត ទីណា** រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល អនុប្រធាន

៥-ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន

៦-ឯកឧត្តម **ប្រាក់ ខួនហុង** អគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៧-ឯកឧត្តមវេជ្ជបណ្ឌិត **ហុក គីមចេង** អគ្គនាយកបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល អនុប្រធាន

៨-ឯកឧត្តម **សុខ សំអោង** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងសុខាភិបាល អនុប្រធាន

៩-ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ី សាគុណា** អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន

១០-ឯកឧត្តម **ម៉ក់ ស៊ីដេត** អគ្គនាយកដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

១១-ឯកឧត្តម **យឹម គន្ធី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១២-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឃុន សំបូរ** អគ្គនាយករងអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

១៣-ឯកឧត្តមនាយឧត្តមសេនីយ៍ **ពិន ពិសិដ្ឋ** អគ្គនាយករងអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

១៤-ឯកឧត្តមឧត្តមសេនីយ៍ឯក **ស រដ្ឋា** អគ្គនាយករងអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

១៥-ឯកឧត្តមឧត្តមសេនីយ៍ឯក **ពេជ្រ ឈឿន** អគ្គនាយករងភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ សមាជិក

១៦-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឆាយ គីមខឿន** អគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក

១៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **ថោង ថាវរិទ្ធ** មេបញ្ជាការរងកងទ័ពជើងគោកក្រសួងការពារជាតិ សមាជិក

១៨-ឯកឧត្តម **គីម កែវមុនីរ័ត្ន** អគ្គនាយករងថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៩-លោក **ហ៊ីន ហួង** អគ្គនាយករងបច្ចេកទេសសុខាភិបាលក្រសួងសុខាភិបាល សមាជិក

២០-លោក **ឆា អេងវ៉េង** អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ជា អេងឃ៉ុង** ស្នងការនៃស្នងការដ្ឋានស្រាវជ្រាវព័ត៌មានសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២២-លោកឧត្តមសេនីយ៍ទោ **សុគន្ធ ចិសាល** នាយកនាយកដ្ឋានរដ្ឋបាលនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច ក្រសួងការពារជាតិ សមាជិក

២៣-ឯកឧត្តមឧត្តមសេនីយ៍ទោ **យន្ត ដឹក** នាយកនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេសនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ សមាជិក

២៤-ឯកឧត្តមឧត្តមសេនីយ៍ទោ **ឌួង ឧត្តម** នាយកនាយកដ្ឋានប្រតិបត្តិការក្រៅប្រទេសនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ សមាជិក

២៥-ឯកឧត្តម **គីម សេរីរដ្ឋ** ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍និងម្ហូបអាហារ ក្រសួងទេសចរណ៍ សមាជិក

២៦-ឯកឧត្តម **ឈុន មករា** ប្រធាននាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារដឹកជញ្ជូននិងមគ្គុទ្ទេសក៍ទេសចរណ៍ ក្រសួងទេសចរណ៍ សមាជិក

២៧-ឯកឧត្តម **ទ៉ាន់ ចន្ទី** ប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

២៨-លោក **គាន់ ពុទ្ធី** អនុប្រធាននាយកដ្ឋានបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

២៩-ឯកឧត្តម-លោកជំទាវ អភិបាលរាជធានី-ខេត្ត ទទួលបន្ទុកការងារចត្តាឡីស័ក សមាជិក។

**III-អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវអេបុគ្គលផ្ទុកមេរោគកូវីដ-១៩**

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តមវេជ្ជបណ្ឌិត **លី សូវ៉ាន់** ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល អនុប្រធាន

៣-លោក **លី សុផាណា** ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ អនុប្រធាន

៤-ឯកឧត្តម **ទេស រុក្ខាផល** អគ្គលេខាធិការនៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្មបាតុកម្មនៅតាមគ្រប់មុខសញ្ញា សមាជិក

៥-ឯកឧត្តម **ជាង សុភ័ក្ត្រ** អគ្គនាយកគ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

៦-ឯកឧត្តមឧត្តមសេនីយ៍ឯក **សាយ ម៉េងឈាង** អគ្គនាយករងអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ សមាជិក

៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ វាសនា** អគ្គនាយករងអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

៨-ឯកឧត្តម **ទួន ផារ័ត្ន** អភិបាលរងរាជធានីភ្នំពេញ សមាជិក

៩-ឯកឧត្តម **ហង្ស ហេម** អគ្គលេខាធិការរងនៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្មបាតុកម្មនៅតាមគ្រប់មុខសញ្ញា សមាជិក

១០-លោកឧត្តមសេនីយ៍ត្រី **ចាន់ សុខឿន** ស្នងការរងស្នងការដ្ឋានស្រាវជ្រាវព័ត៌មាននិងសន្តិសុខនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១១-លោក **ឈន វិបុល** ប្រធាននាយកដ្ឋានព័ត៌មានវិទ្យាក្រសួងព័ត៌មាន សមាជិក

១២-ឯកឧត្តម **សៅ វឌ្ឍនា** នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

១៣-លោកវេជ្ជបណ្ឌិត **ចាន់ សុភ័ស្ត** នាយករងមន្ទីរពេទ្យមិត្តភាព កម្ពុជា-ចិន ព្រះកុសុមៈ និងជាតំណាងក្រុមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) សមាជិក។

**IV-អនុគណៈកម្មការបច្ចេកទេស និងព្យាបាល**

១-ឯកឧត្តមសាស្ត្រាចារ្យ **ហ៊ុន ចំរើន** រដ្ឋលេខាធិការក្រសួងសុខាភិបាល ប្រធាន

២-លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** អនុប្រធានក្រុមប្រឹក្សាភិបាល សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) អនុប្រធានអចិន្ត្រៃយ៍

៣-ឯកឧត្តមវេជ្ជបណ្ឌិត **ខ៊ូវ ភាង** រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

៤-ឯកឧត្តមវេជ្ជបណ្ឌិត **ហុក គឹមចេង** អគ្គនាយកបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល អនុប្រធាន
៥-ឯកឧត្តមសាស្ត្រាចារ្យ **ឌី ម៉េង** នាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត អនុប្រធាន
៦-លោកវេជ្ជបណ្ឌិត **ស៊ូ ស៊ីផាណ្ណា** នាយករងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត អនុប្រធាន
៧-លោកសាស្ត្រាចារ្យ **ចាប សៀកឆាយ** អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល សមាជិក
៨-លោកវេជ្ជបណ្ឌិត **ហួយ សេរីវឌ្ឍន:** អគ្គនាយករងបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល សមាជិក
៩-លោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** ប្រធាននាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល សមាជិក
១០-លោកសាស្ត្រាចារ្យរង **អ៊ិត ម៉** នាយករងវិទ្យាស្ថានជាតិសុខភាពសាធារណៈ សមាជិក
១១-លោកស្រីឱសថការី **ទ៉ា ពុធនាថ** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល សមាជិក
១២-លោកសាស្ត្រាចារ្យ **គឹម ឈួង** អនុប្រធានមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ សមាជិក
១៣-លោកសាស្ត្រាចារ្យ **នី ចន្ទី** អនុប្រធានការិយាល័យបច្ចេកទេសមន្ទីរពេទ្យមិត្តភាព កម្ពុជា-ចិន ព្រះកុសុមៈ សមាជិក
ថ្ងៃ...ចន្ទ ១៤រោច.....ខែ.អាសាឍ...ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២០.....ខែ.កក្កដា.....ឆ្នាំ២០២០

**ជ. រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុន-ហ៊ុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៣ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ : ០៣៤ ក.ស.យ.ប្រ.ក/២១

# ប្រកាស

## ស្តីពី

## ការលុបឈ្មោះមន្ត្រីរាជការ

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញលិខិតលេខ ០១ អ.ក.អ/២០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់នាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស ស្តីពីការសុំផ្តល់ជូននូវរបាយការណ៍មរណភាពរបស់លោក ម៉េង ជាហេង អនុប្រធាននាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស នៃក្រសួងយុត្តិធម៌
- បានឃើញលិខិតលេខ ០២ ប.ល/២១ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់នាយកដ្ឋានកិច្ចការបុគ្គលិក ស្តីពីសំណើសុំលុបឈ្មោះមន្ត្រីរាជការចំនួន ២ រូប ចេញពីក្របខណ្ឌក្រសួងយុត្តិធម៌
- បានឃើញសេចក្តីចម្លងសំបុត្រមរណភាពលេខ ៩១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ របស់សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

- បានឃើញសេចក្តីចម្លងសំបុត្រមរណភាពលេខ ២៣ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
- បានឃើញសេចក្តីចម្លងសំបុត្រមរណភាពលេខ ៣១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង

## សម្រេច

**ប្រការ១ .-**

ត្រូវបានលុបឈ្មោះមន្ត្រីរាជការចំនួន **៣ រូប** ចេញពីក្របខណ្ឌក្រសួងយុត្តិធម៌ ចាប់ពី**ថ្ងៃទី០១ ខែមករា ឆ្នាំ២០២១** តទៅ ដោយមូលហេតុសាមីខ្លួនទទួលមរណភាព ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | អត្តលេខ | ប្រភេទក្របខណ្ឌ | មុខតំណែង | អង្គភាព |
|---|---|---|---|---|---|
| ១ | លោក **ម៉េង ជាហេង** | ១៧៤០២០០០១៦ | ក.១.៦ | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស |
| ២ | លោក **ម៉ៅ បូរី** | ១៧២២១០០២៥៤ | ក.១.៦ | ប្រធានការិយាល័យ | នាយកដ្ឋានកិច្ចការបុគ្គលិក |
| ៣ | លោក **ឈន លាង** | ៣០៩៩១៧០១១១ | គ្មានក្របខណ្ឌ | ជំនួយការអមក្រសួងយុត្តិធម៌ | ទីស្តីការក្រសួងយុត្តិធម៌ |

**ប្រការ២ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៣៧.ក.យ.ប្រ.ក/២១

# ប្រកាស

## ស្តីពី

## ការលុបឈ្មោះមន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២០/១១៩៦ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការតែងតាំងចៅក្រមកម្មសិក្សា ព្រះរាជអាជ្ញារងកម្មសិក្សា ចំនួន ៥៥ នាក់ ឱ្យទៅបម្រើការងារនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមពាក្យសុំរបស់សាមីខ្លួន

## សម្រេច

**ប្រការ១ .-**

ត្រូវបានលុបឈ្មោះមន្ត្រីរាជការចំនួន **៣ រូប** ចេញពីក្របខណ្ឌក្រសួងយុត្តិធម៌ ចាប់ពី**ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០** តទៅ ដោយមូលហេតុសាមីខ្លួនត្រូវបានតែងតាំងជាចៅក្រមកម្មសិក្សា នៅសាលាដំបូងខេត្តនានា ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | អត្តលេខ | ប្រភេទ ក្របខណ្ឌ | មុខតំណែង | អង្គភាព |
|---|---|---|---|---|---|
| ១ | លោក **ប៊ិន ប៊ុនធិល** | ១៨៥១៤០០២៩៧ | ក.២.២ | អគ្គនាយករង | អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ |
| ២ | លោក **ផុង ពិសិដ្ឋ** | ១៧២២១០០០១៧ | ក.១.២ | អគ្គាធិការរង | អគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ៣ | លោក **អែម សុសច្ចា** | ១៩០១២០០២៦៩ | ក.៣.៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី |

**ប្រការ២.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល :**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងមុខងារសាធារណៈ
- -ដូចប្រការ២
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៣៧ ក.យ.ស.ប្រក/២១

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌នៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

### ប្រការ១ .-

ប្រកាសនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ សរសេរជាអក្សរកាត់ថា "**ល.ក.ន.យ.**"។



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

**ប្រការ២ ._**

**លភ.ន.យ.** បំពេញមុខងារជាសេនាធិការឱ្យក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ (**ភ.ន.យ.**) លើកិច្ចការបច្ចេកទេសច្បាប់, កិច្ចការស្រាវជ្រាវ និងវិភាគ និងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈ ដូចតទៅ៖

- ជួយ **ភ.ន.យ.** លើការសិក្សា ស្រាវជ្រាវ និងការលើកយោបល់បច្ចេកទេសជូនក្រសួងយុត្តិធម៌ ចំពោះរាល់ការងារដែលជាសមត្ថកិច្ចរបស់ **ភ.ន.យ.** ដូចមានកំណត់ក្នុងមាត្រា២ នៃអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌
- ជួយ **ភ.ន.យ.** លើការវិភាគនយោបាយ និងគោលនយោបាយផ្នែកច្បាប់ ព្រមទាំងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលអាចជាមូលដ្ឋានដល់ការអភិវឌ្ឍវិស័យច្បាប់ យុត្តិធម៌ និងអភិបាលកិច្ច
- សម្របសម្រួល និងទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់ **ភ.ន.យ.**
- រៀបចំ និងសម្របសម្រួលកម្មវិធីការងារ កិច្ចប្រជុំ បេសកកម្ម និងពិធីការផ្សេងៗរបស់ **ភ.ន.យ.**
- គ្រប់គ្រងការងារបុគ្គលិកក្នុង **លភ.ន.យ.**
- ទទួលបន្ទុករៀបចំ និងគ្រប់គ្រងថវិកា ទ្រព្យសម្បត្តិ បញ្ជីសារពើភណ្ឌ សន្និធិសម្ភារៈ សម្រាប់បម្រើការងារក្នុង **ភ.ន.យ.**
- រៀបចំបែបបទទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងអង្គការជាតិ និងអន្តរជាតិនានា
- រៀបចំឯកសារ របាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំ និងកម្មវិធីផ្សេងៗរបស់ **ភ.ន.យ.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **ភ.ន.យ.**
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ភ.ន.យ.**។

**ប្រការ៣ ._**

**លភ.ន.យ.** មានរចនាសម្ព័ន្ធ ដូចតទៅ៖

- ការិយាល័យកិច្ចការទូទៅ
- ការិយាល័យកិច្ចការច្បាប់
- ការិយាល័យកិច្ចការយុត្តិធម៌
- ការិយាល័យកិច្ចការស្រាវជ្រាវ និងវិភាគ។

អង្គការលេខរបស់ **លភ.ន.យ.** ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤ ._**

ការិយាល័យកិច្ចការទូទៅ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- គ្រប់គ្រងការងាររដ្ឋបាល លិខិតចេញ-ចូល និងឯកសាររដ្ឋបាលនានា
- គ្រប់គ្រងការងារបុគ្គលិក

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិការបស់ **ល.ក.ន.យ.**
- គ្រប់គ្រងចលនវត្ថុ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌរបស់ **ក.ន.យ.**
- ទំនាក់ទំនងសម្របសម្រួលស្នើសុំថវិកា និងធ្វើរបាយការណ៍ទូទាត់ចំណូល-ចំណាយថវិកា សម្ភារៈ និងបរិក្ខារផ្សេងៗ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **ក.ន.យ.**
- រៀបចំ និងសម្របសម្រួលកម្មវិធីការងារ បេសកកម្ម និងពិធីការផ្សេងៗរបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- រៀបចំ និងសម្របសម្រួលរាល់កិច្ចប្រជុំ និងកម្មវិធីផ្សេងៗរបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- សម្របសម្រួលការងារទំនាក់ទំនងជាមួយអគ្គនាយកដ្ឋាន និងអង្គភាពផ្សេងៗចំណុះឱ្យក្រសួងយុត្តិធម៌ ការងារទំនាក់ទំនងសាធារណៈ និងការគ្រប់គ្រងបណ្តាញសង្គមរបស់ **ក.ន.យ.**
- រៀបចំ និងចងក្រងសម្រាប់ការបោះពុម្ពនូវព្រឹត្តិបត្រ និងឯកសារស្រាវជ្រាវផ្សេងៗរបស់ **ក.ន.យ.**
- រៀបចំ និងបូកសរុបផែនការការងាររបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- ធ្វើរបាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំរបស់ **ក.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ល.ក.ន.យ.**។

ការិយាល័យកិច្ចការទូទៅ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៥ ._**

ការិយាល័យកិច្ចការច្បាប់ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងលើកយោបល់ទាក់ទងនឹងសង្គតិភាព និងអនុលោមភាពគតិយុត្តនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ជាមួយនិងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សិក្សាស្រាវជ្រាវ និងលើកយោបល់ទាក់ទងនឹងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ព្រមទាំងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យយុត្តិធម៌ ជាមួយនិងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងវិស័យយុត្តិធម៌
- សិក្សាស្រាវជ្រាវ និងវាយតម្លៃអំពីផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យច្បាប់ និងយុត្តិធម៌

- ចូលរួមជាមួយអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ក្នុងការរៀបចំចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ដើម្បីផ្សព្វផ្សាយ ក៏ដូចជាការរៀបចំ និងបោះពុម្ពផ្សាយព្រឹត្តិបត្រច្បាប់ ជាដើម
- ចូលរួមរៀបចំផែនការការងាររបស់ **គ.ន.យ.** និង **លគ.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **លគ.ន.យ.**។

ការិយាល័យកិច្ចការច្បាប់ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៦ .-**

ការិយាល័យកិច្ចការយុត្តិធម៌ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីតម្រូវការក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់សម្រាប់បម្រើឱ្យវិស័យយុត្តិធម៌ និងអំពីភាពចាំបាច់នានាក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យយុត្តិធម៌
- សិក្សាស្រាវជ្រាវអំពីប្រព័ន្ធយុត្តិធម៌ និងការផ្តល់សេវាយុត្តិធម៌ ក៏ដូចជាយន្តការដោះស្រាយវិវាទនានានៅក្នុងបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីបានជាធាតុចូលក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ កិច្ចដំណើរការល្អនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅកម្ពុជា ព្រមទាំងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីតម្រូវការចាំបាច់ក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ ក៏ដូចជាកិច្ចដំណើរការនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ចូលរួមសហការតាមការចាំបាច់ជាមួយនឹងអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ សំដៅបង្កើនប្រសិទ្ធភាពនៃការគោរពច្បាប់ និងអនុវត្តច្បាប់
- ចូលរួមរៀបចំផែនការការងាររបស់ **គ.ន.យ.** និង **លគ.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **លគ.ន.យ.**។

ការិយាល័យកិច្ចការយុត្តិធម៌ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៧ .-**

ការិយាល័យកិច្ចការស្រាវជ្រាវ និងវិភាគ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងវិភាគអំពីនយោបាយ និងគោលនយោបាយផ្នែកច្បាប់ យុត្តិធម៌ និងអភិបាលកិច្ច

- តាមដាន ប្រមូល និងវិភាគព័ត៌មានសំខាន់ៗទាក់ទងនឹងបច្ចុប្បន្នភាព និងការវិវត្តនៃវិស័យច្បាប់ និងយុត្តិធម៌ នៅក្នុងប្រទេស តំបន់ និងពិភពលោក ដែលអាចជាមូលដ្ឋានក្នុងការរៀបចំគោល-នយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- សិក្សាស្រាវជ្រាវ និងលើកយោបល់អំពីតម្រូវការចាំបាច់ ក្នុងការធ្វើបច្ចុប្បន្នភាពច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី និងវិស័យផ្សេងទៀត
- ចូលរួមរៀបចំផែនការការងាររបស់ **ក.ន.យ.** និង **ល.ក.ន.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន **ល.ក.ន.យ.**។

ការិយាល័យកិច្ចការស្រាវជ្រាវ និងវិភាគ ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាល ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៨ ..**

មន្ត្រីដែលបំពេញការងារនៅ **ល.ក.ន.យ.** គឺជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនៅក្រសួងយុត្តិធម៌។ ក្នុងករណីចាំបាច់ ប្រធាន **ល.ក.ន.យ.** អាចស្នើសុំទៅប្រធាន **ក.ន.យ.** ដើម្បីជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារ ដោយអនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន។

**ប្រការ៩ ..**

ដើម្បីបំពេញតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រកាសនេះ **ល.ក.ន.យ.** ប្រើប្រាស់ធនធានថវិកា និងហិរញ្ញវត្ថុរបស់ **ក.ន.យ.** ដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌។

**ប្រការ១០ ..**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ គ្រប់អគ្គនាយក អគ្គាធិការ ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌នៃក្រសួងយុត្តិធម៌ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០៣៧កយ.ប្រក/ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

អង្គការលេខរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៣៨ ក.យធ.ប្រក/២១

# ប្រកាស

## ស្ដីពី

## ការលុបឈ្មោះមន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ ស្ដីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិកកម្មកររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្ដងគត់ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមពាក្យសុំរបស់សាមីខ្លួន

## សម្រេច

**ប្រការ១ .-**

ត្រូវបានលុបឈ្មោះលោក **អ៊ីវ វិចិត្រ** អត្តលេខ ១៨១១២០០៦៤៤ ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៣ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មុខតំណែងជាមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅអគ្គលេខាធិការដ្ឋាននៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ចេញពីក្របខណ្ឌក្រសួងយុត្តិធម៌ ចាប់ពី**ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១** តទៅ ដោយមូលហេតុសាមីខ្លួនសុំលាឈប់ពីការងារ។ សាមីខ្លួនត្រូវបានទទួលប្រាក់ឧបត្ថម្ភម្ដងគត់ ស្មើនឹងប្រាក់បៀវត្សមូលដ្ឋានចុងក្រោយគុណ ៣។

**ប្រការ២ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាននៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សៅរ៍ ១៣កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៤១ កយរ.ប្រក.២១

# ប្រកាស
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

# សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងលោក **ស៊ិន់ សំ** អត្តលេខ**១៩៣០៣០០១៩៣** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៣ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធានការិយាល័យរដ្ឋបាលទូទៅ នៃនាយកដ្ឋានកិច្ចការរដ្ឋបាល នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ព្រះសីហនុ។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងយុត្តិធម៌ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ព្រះសីហនុ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក នៃសាលាជម្រះក្តី លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីខេត្ត ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៤ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលាជម្រះក្តី នៃព្រះរាជាណាចក្រកម្ពុជា
- អង្គភាពរដ្ឋបាល នៃសាលាជម្រះក្តី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :.០៤២.កឃ.ប្រក/២១

# ប្រកាស
## ស្តីពី
## ការផ្លាស់មន្ត្រីរាជការ

### រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមលិខិតលេខ ១២៦ មស.គ្ររ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ

### សម្រេច

**ប្រការ១ .-**

ត្រូវបានផ្លាស់លោកស្រី **កែប សុខេម៉ា** អត្តលេខ ២៨២១២០០៣៧៩ ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល បច្ចុប្បន្នជាប្រធានការិយាល័យគ្រប់គ្រងថវិកា នៅនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ក្នុងក្របខណ្ឌក្រសួងយុត្តិធម៌ ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងធនធានទឹក និងឧតុនិយម។

**ប្រការ២ .-**

ប្រាក់បៀវត្ស និងប្រាក់បន្ថាប់បន្សំ នៃបៀវត្សរបស់សាមីខ្លួន ត្រូវបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីបញ្ជីបើកប្រាក់របស់អង្គភាពដើម។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៤ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០៤៧.គឃ.ប្រក.២១

# ប្រកាស

## ស្តីពី

## ការផ្ទេរភារកិច្ច តែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- បានឃើញប្រកាសលេខ ១៣៣ កយ.ប្រក/១៦ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងយុត្តិធម៌ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននានានៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្ទេរភារកិច្ចលោក **សុខ កុសល** អត្តលេខ ១៩៣០៤០០១០២ ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ពីអនុប្រធានលេខាធិការដ្ឋាន នៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តតាកែវ ទៅជាអនុប្រធានលេខាធិការដ្ឋាន នៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះសីហនុ។

**ប្រការ២ .-**

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន **២រូប** នៅតាមអង្គភាពនានានៃក្រសួងយុត្តិធម៌ ដូចមានរាយនាមខាងក្រោម ៖

១. លោក **ជៀវ សេងហួរ** អត្តលេខ ១៨៦១២០០២៥៩ ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាប្រធានការិយាល័យព័ត៌មានវិទ្យា នៅនាយកដ្ឋានបូកសរុប បណ្ណាសា និងព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌

២. លោក **ជា ប៊ុនថាវី** អត្តលេខ ១៩១១៩០០០៥៣ ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៣ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាអនុប្រធានការិយាល័យកិច្ចការអយ្យការនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តស្ទឹងត្រែង។

**ប្រការ៣ .-**

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន **៣រូប** នៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តស្ទឹងត្រែង ដូចមានរាយនាមខាងក្រោម ៖

១. លោក **កាល់ បញ្ញា** អត្តលេខ ១៩៤១៤០០១០៥ ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីក្រមការ ឲ្យបំពេញមុខងារជាប្រធានការិយាល័យកិច្ចការតុលាការ ជំនួសលោក កាល់ ធិកា ដែលបានស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស

២. លោក **ភួន សុភត្រា** អត្តលេខ ១៨៩១៩០០០៦៨ ឋានន្តរស័ក្តិ លេខាធិការរដ្ឋបាល ថ្នាក់លេខ ១០ នៃក្របខណ្ឌលេខាធិការរដ្ឋបាល ឲ្យបំពេញមុខងារជាអនុប្រធានការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក

៣. លោក **ម៉ាន់ សុខៈ** អត្តលេខ ១៨៨១៩០០០២៣ ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីក្រមការ ឲ្យបំពេញមុខងារជាអនុប្រធានការិយាល័យកិច្ចការហិរញ្ញវត្ថុ។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងយុត្តិធម៌ អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៤៨ កសរ.ប្រក/២១

# ប្រកាស
## ស្តីពី
## ការដាក់មន្ត្រីរាជការ
## ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.តត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមពាក្យសុំរបស់សាមីខ្លួន

## សម្រេច

**ប្រការ១ .-**

ត្រូវបានអនុញ្ញាតលោកស្រី **ប៊ុន ច័ន្ទមករា** អត្តលេខ ២៨៤១២០០២២៩ ឋាននន្តរស័ក្តិ អនុមន្ត្រីថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មុខតំណែងជាប្រធានការិយាល័យជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ នៅនាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងបត្យាប័ន នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល ២ ឆ្នាំ គិតចាប់ពី**ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣**។

**ប្រការ២ .-**

សិទ្ធិទទួលប្រាក់បៀវត្ស ឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ និងអតីតភាពការងារសម្រាប់សោធននិវត្តន៍របស់សាមីខ្លួន ត្រូវកាត់ផ្តាច់ក្នុងរយៈពេលដែលសាមីខ្លួនស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស។

**ប្រការ៣ .-**

សាមីខ្លួនត្រូវដាក់ពាក្យសុំចូលបម្រើការងាររបស់ខ្លួនវិញ ឲ្យបាន ២ ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស នឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌរបស់ក្រសួង ក្នុងករណីដែលសាមីខ្លួនមិនចូលបម្រើការងារនៅថ្ងៃបញ្ចប់ភាពទំនេរគ្មានបៀវត្ស។ សាមីខ្លួនអាចចូលបម្រើការងារក្នុងមុខតំណែងរបស់ខ្លួនវិញបាន ក្នុងករណីដែលកន្លែងនោះនៅទំនេរពុំទាន់មានមន្ត្រីមកជំនួស។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៤៨ ក.ឃ.ស.ប្រក.២១

# ប្រកាស
## ស្តីពី
## ការដាក់មន្ត្រីរាជការ
## ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ

### រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.តត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមរបាយការណ៍របស់គណៈកម្មការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់នៃមន្ត្រីរាជការស៊ីវិលរបស់ក្រសួងយុត្តិធម៌ សម្រាប់ឆ្នាំ២០២១

### សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់មន្ត្រីរាជការចំនួន **៨រូប** នៅទីស្តីការក្រសួងយុត្តិធម៌ ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ រយៈពេល **៣ខែ គិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១** ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | | អត្តលេខ | ប្រភេទ ក្របខណ្ឌ | មុខតំណែង | អង្គភាព |
|---|---|---|---|---|---|---|
| ១ | លោក | តាន់ មុនីវណ្ណ | ១៧៣០៣០០២៥៧ | ក.២.១ | អធិការ | អគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ២ | លោក | ប៊ុន ច័ន្ទកុម្ភៈ | ១៨២០៨០០៣៦៤ | ក.២.៤ | អធិការ | អគ្គាធិការដ្ឋានកិច្ចការតុលាការ |
| ៣ | លោក | នូ សក្តី | ១៨០១២០០៣២៥ | ក.២.៣ | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងយុត្តិធម៌អនីតិជន |

| | | | | | |
|---|---|---|---|---|---|
| ៤ | លោកស្រី **ឆៃ សុគន្ធារី** | ២៨១០៨០០២៦១ | ក.២.២ | អនុប្រធានការិយាល័យសម្របសម្រួលកិច្ចការព្រហ្មទណ្ឌ | នាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងបត្យាប័ន |
| ៥ | លោក **ចាន់ មុន្នី** | ១៨៨១៨០០០៦១ | ក.៣.៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | នាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងបត្យាប័ន |
| ៦ | លោកស្រី **សំបូរ សម្ផស្ស** | ២៨៦១២០០១៧០ | ក.៣.២ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | នាយកដ្ឋានកិច្ចការបុគ្គលិក |
| ៧ | លោកស្រី **សុខ អាវស្រីលក្ខណ៍** | ២៨៩១២០០១០៦ | ក.៣.៣ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | នាយកដ្ឋានកិច្ចការបុគ្គលិក |
| ៨ | លោក **ខែក ខេមរៈ** | ១៨១០៣០០៤០០ | ក.៣.៣ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | នាយកដ្ឋានសវនកម្មផ្ទៃក្នុង |

**ប្រការ២ .-**

សិទ្ធិទទួលប្រាក់បៀវត្ស ឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ និងអតីតភាពការងារសម្រាប់សោធននិវត្តន៍របស់សាមីខ្លួន ត្រូវកាត់ផ្តាច់ក្នុងរយៈពេលដែលសាមីខ្លួនស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស។

**ប្រការ៣ .-**

សាមីខ្លួនត្រូវទៅបង្ហាញខ្លួន និងចូលបម្រើការងារនៅអង្គភាពសាមីក្នុងអំឡុងពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស នឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌរបស់ក្រសួង ក្នុងករណីដែលសាមីខ្លួនមិនចូលបម្រើការងារនៅថ្ងៃបញ្ចប់ភាពទំនេរគ្មានបៀវត្ស។ សាមីខ្លួនអាចចូលបម្រើការងារក្នុងមុខតំណែងរបស់ខ្លួនវិញបាន ក្នុងករណីដែលកន្លែងនោះនៅទំនេរពុំទាន់មានមន្ត្រីមកជំនួស។

**ប្រការ៤ .-**

ប្រធានអង្គភាពសាមី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការដាក់ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ផ្ញើមកក្រសួងនៅថ្ងៃបញ្ចប់នៃភាពទំនេរគ្មានបៀវត្សនេះ។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ៤៨/២០ ក.ធ.ស.សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការអនុញ្ញាតឱ្យកសាងព្រះវិហារ**

**រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និង សាសនា
- បានឃើញសេចក្តីសម្រេចលេខ ៤២ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីគោលការណ៍គ្រប់គ្រងវត្តអារាម និងទ្រព្យសម្បត្តិគរុភណ្ឌសង្ឃ
- យោងតាមសំណើសុំចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ របស់ព្រះចៅអធិការ គណៈកម្មការ អាចារ្យវត្តបទុម ស្ថិតក្នុងភូមិបទុមលិច ឃុំរុងរឿង ស្រុកស្ទោង ខេត្តកំពង់ធំ

**សម្រេច**

**ប្រការ១.-**

អនុញ្ញាតឱ្យកសាង **ព្រះវិហារវត្តបទុម** ស្ថិតនៅក្នុងភូមិបទុមលិច ឃុំរុងរឿង ស្រុកស្ទោង ខេត្តកំពង់ធំ តាមរចនាបថព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែរ ដោយសហការជាមួយអាជ្ញាធរជំនាញពាក់ព័ន្ធនានា ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងគុណភាពសំណង់។

**ប្រការ២.-**

ព្រះវិហារថ្មីនេះ ត្រូវដាក់ឱ្យពុទ្ធសាសនិកគោរពប្រតិបត្តិ និងប្រារព្ធពិធីសាសនា ស្របទៅតាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងច្បាប់ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា៕ល៕

ស្មូនច្បារសម្តេច ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ សម្តេចព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសាសនា ប្រធានមន្ទីរធម្មការ និងសាសនាខេត្តកំពង់ធំ ប្រធានអង្គភាពដែលពាក់ព័ន្ធ និងគណៈកម្មការ អាចារ្យវត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

ឈិត_សុខុន

**កន្លែងទទួល :**

- គណៈសង្ឃនាយកនៃគណៈមហានិកាយ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- រដ្ឋបាលខេត្តកំពង់ធំ
- សាលាគណខេត្តកំពង់ធំ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ៤៩៦/២០ ក.ធ.ស.ប្រក

## ប្រកាស
## ស្តីពី
## ការប្រែក្លាយអាស្រម ទៅជាវត្ត នៃគណៈមហានិកាយ

## រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និង សាសនា
- បានឃើញសង្ឃប្រកាសលេខ ២០/១៣ ស.ន.ក.ជ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការសម្រេចឱ្យប្រែក្លាយអាស្រមទូទាំងប្រទេស ទៅជាវត្តពុទ្ធសាសនាវិញ
- យោងតាមសំណើសុំចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ របស់ព្រះសង្ឃ អាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទភូមិដងរែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដោយមានការឯកភាពពីអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់

## សម្រេច

**ប្រការ១.-**

អនុញ្ញាតឱ្យប្រែក្លាយអាស្រម គិរីរុក្ខារាមដងរែក ទៅជា **វត្តគិរីរុក្ខារាមដងរែក** ស្ថិតនៅភូមិដងរែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ តាមរចនាបថព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែរ។

វត្តថ្មីនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រងដឹកនាំរបស់គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងដោយមានការសហការពីអាជ្ញាធរពាក់ព័ន្ធ។៖

សួនច្បារសម្តេច ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៥៥ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីមែល : ministry religion@yahoo.com Web site : www.mocar.gov.kh

**ប្រការ២.**

វត្តថ្មីនេះ ត្រូវដាក់ឱ្យពុទ្ធសាសនិកគោរពប្រតិបត្តិ និងប្រារព្ធពិធីសាសនា ស្របទៅតាមពុទ្ធបញ្ញត្តិ ពុទ្ធានុញ្ញាត និងច្បាប់ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.**

វត្តថ្មីនេះ ត្រូវបានដឹកនាំដោយព្រះចៅអធិការមួយអង្គ ដែលអមដោយសហការី និងគណៈកម្មការអាចារ្យវត្ត ជាជំនួយការតាមការចាំបាច់។

**ប្រការ៤.**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវត្ត ត្រូវអនុលោមតាមសង្ឃប្រកាសរបស់គណៈសង្ឃនាយកគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា លិខិតបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិពាក់ព័ន្ធនានា និងសេចក្តីណែនាំចេញដោយក្រសួងធម្មការ និង សាសនា។

**ប្រការ៥.**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ សម្តេចព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសាសនា ប្រធានមន្ទីរធម្មការ និងសាសនាខេត្តបន្ទាយមានជ័យ និងប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

ឈិត-សុខុន

**កន្លែងទទួល :**

- សម្តេចព្រះមហាសង្ឃរាជនៃគណៈមហានិកាយ
- គណៈសង្ឃនាយកនៃគណៈមហានិកាយ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
- សាលាគណខេត្តបន្ទាយមានជ័យ
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ២២១/២១ ក.ធ.ស.ប្រក

## ប្រកាស

## ស្តីពី

## ការបង្កើតវត្ត នៃគណៈធម្មយុត្តិកនិកាយ

## រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧២៦ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និង សាសនា
- យោងតាមសំណើសុំចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២០ របស់ព្រះត្បូងឃ្មុំបទុមព្រហ្មវិហារមុនី លីម គឹមឡុង ព្រះរាជាគណៈថ្នាក់កិត្តិយស ព្រះរាជឧបការីសម្តេចព្រះមហាសង្ឃរាជ និងជាព្រះសិរីកូមវង្ស ព្រះមេគណគណៈធម្មយុត្តិកនិកាយខេត្តត្បូងឃ្មុំ

## សម្រេច

**ប្រការ១.-**

ត្រូវបានអនុញ្ញាតឱ្យបង្កើត **វត្តជុំគិរីតេជោសែនជ័យ** ស្ថិតនៅភូមិថ្មីសែនជ័យ ឃុំទួលសូភី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ តាមរចនាបថព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែរ។

វត្តថ្មីនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រងដឹកនាំរបស់គណៈសង្ឃនាយកគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងដោយមានការសហការពីអាជ្ញាធរពាក់ព័ន្ធ។

**ប្រការ២.-**

វត្តថ្មីនេះ ត្រូវដាក់ឱ្យពុទ្ធសាសនិកគោរពប្រតិបត្តិ និងប្រារព្ធពិធីសាសនា ស្របទៅតាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងច្បាប់ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។ ៚

**ប្រការ៣.-**

វត្តថ្មីនេះ ត្រូវបានដឹកនាំដោយព្រះចៅអធិការមួយអង្គ ដែលអមដោយសហការី និងគណៈកម្មការអាចារ្យវត្ត ជាជំនួយការតាមការចាំបាច់។

**ប្រការ៤.-**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវត្ត ត្រូវអនុលោមតាមសង្ឃប្រកាសរបស់គណៈសង្ឃនាយកគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា លិខិតបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិពាក់ព័ន្ធនានា និងសេចក្តីណែនាំចេញដោយក្រសួងធម្មការ និង សាសនា ។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ សម្តេចព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសាសនា ប្រធាននាយកដ្ឋានកិច្ចការព្រះពុទ្ធសាសនា ប្រធានមន្ទីរធម្មការ និង សាសនាខេត្តត្បូងឃ្មុំ និងប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១
រដ្ឋមន្ត្រី

ឈិត-សុខុន

**កន្លែងទទួល** :
- សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
- គណៈសង្ឃនាយកនៃគណៈធម្មយុត្តិកនិកាយ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលខេត្តត្បូងឃ្មុំ
- សាលាគណខេត្តត្បូងឃ្មុំ
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី